ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លេខ.....✓............. រ.ប.ក

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ**: - **លោកឧត្តមសេនីយ៍ទោ ហាង ជីវ័ន្ត ប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប**

- **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ**

**កម្មវត្ថុ**: ស្តីពី កិច្ចប្រជុំកម្រិតបច្ចេកទេស ពិនិត្យ ពិភាក្សា ឆ្លងរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២៣ និងត្រៀមរបាយការណ៍ឆ្នាំ២០២៣ រួមទាំងការប្រមូលធាតុចូលវាយតម្លៃផែនការយុទ្ធសាស្ត្របន្តពីថ្នាក់ជាតិ៥ឆ្នាំបន្ទាប់(២០២៤-២០២៨)។

ថ្ងៃសុក្រ ៣ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៨:៣០ នាទីព្រឹក នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេស ពិនិត្យ ពិភាក្សា ឆ្លងរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២៣ និងត្រៀមរបាយការណ៍ឆ្នាំ២០២៣ រួមទាំងការប្រមូលធាតុចូលវាយតម្លៃផែនការយុទ្ធសាស្ត្របន្តពីថ្នាក់ជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### I. សមាសភាពចូលរួម

- **ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
- **លោកជំទាវ** អភិបាលរងទទួលផែន រាជធានី/ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ)
- **លោកប្រធាន-អនុប្រធាន** នាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ស្នងការរងទទួលផែន រាជធានី/ខេត្ត
- មន្ត្រីទទួលបន្ទុករបាយការណ៍ និងមន្ត្រីបច្ចេកទេស សរុបចំនួន **៩៧**រូប ស្រី**៥៧**រូប។

### II. មតិស្វាគមន៍

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មាន មតិស្វាគមន៍ និងក្រើនរំលឹកពីតួនាទី ភារកិច្ច និងចេតនាសម្ព័ន្ធថ្នាក់ក្រោមជាតិ។ **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ មានប្រសាសន៍ថា៖ ជាធម្មតាកិច្ចប្រជុំឆ្លងរបាយការណ៍ ១០ខែនេះ តែងធ្វើនៅកំឡុងខែ១០-១១ នៃឆ្នាំនីមួយៗ តែដោយឡែកឆ្នាំ ២០២៣ នេះ ដោយយើងមានការងារច្រើនត្រូវធ្វើ ទើបត្រូវលើកពេលរហូតដល់ពេលនេះ។ គិតត្រឹមរយៈពេល១០ខែ ឆ្នាំ២០២៣នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានប្រមូល និងចងក្រងសកម្មភាពផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ ពីតាមបណ្តារាជធានី ខេត្ត អង្គការដៃគូ រួមមានកិច្ច

ប្រជុំ ការផ្សព្វផ្សាយ និងវេទិកាសាធារណៈ ភូមិឃុំសង្កាត់មានសុវត្ថិភាព និងកម្មវិធីផ្សេងៗ សរុប **១៧១.៣៤០**លើក ចំនួនមនុស្ស **៦.៣៩២.៧៥៥**នាក់ ស្រី ៣.២៥៤.៣៤៧នាក់ បើប្រៀបធៀបរយៈពេល ១០ខែឆ្នាំ២០២២ មានការកើនឡើង **៤១,៩២%**។ ដោយឡែកការងារបណ្ដុះបណ្ដាលពង្រឹងសមត្ថភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចំនួន **៩៧៧**វគ្គ មានសិក្ខាកាមចូលរួមសរុប **៤៨.៨៥៧**នាក់ នារី **២០.៩២១**នាក់។

ជាកិច្ចបន្ទាប់ **លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍** ក៏បានណែនាំសុំឱ្យតាមរាជធានី ខេត្តទាំងអស់ ពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យ តួលេខ និងសកម្មភាពរបស់ខ្លួនឡើងវិញ ដើម្បីកែសម្រួលក្នុងរបាយការណ៍ថ្នាក់ជាតិ ឆ្នាំ២០២៣។ លោកជំទាវ ក៏បានស្នើឱ្យខេត្តដែលមានសកម្មភាពលេចធ្លោ ចែករំលែកនូវបទពិសោធន៍ការងាររបស់ខ្លួន និងបានជជែកពិភាក្សានៅក្នុងកម្មវិធីទាំងមូលផងដែរ។

ជាការឆ្លើយតប ក្នុងកិច្ចប្រជុំមានបណ្ដាខេត្តមួយចំនួន បានធ្វើការកែតម្រូវតួលេខ និងបន្ថែមចំណុចខ្វះខាតមួយចំនួនក្នុងរបាយការណ៍ និងបណ្ដាខេត្តមួយចំនួនទៀត សុំពេលវេលាដើម្បីពិនិត្យ និងកែតម្រូវនៅពេលក្រោយ ដែលលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ បានកំណត់ថា ត្រូវឱ្យបានចប់សព្វគ្រប់នៅពាក់កណ្ដាលខែមករា ឆ្នាំ២០២៤ ជាកំហិត ព្រោះជាពេលដែលយើងត្រូវធ្វើរបាយការណ៍ប្រចាំ និងត្រូវចងក្រងបោះពុម្ពជាសៀវភៅផង។

កិច្ចប្រជុំកម្រិតបច្ចេកទេស ពិនិត្យ ពិភាក្សាឆ្លងរបាយការណ៍រយៈពេល ១០ខែ ឆ្នាំ២០២៣ និងត្រៀមរបាយការណ៍ឆ្នាំ២០២៣ បានបញ្ចប់នៅវេលាម៉ោង ១១:៣០នាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយភាពស្និទ្ធស្នាល និងសោមនស្សរីករាយ។

ដោយឡែកនារសៀលថ្ងៃដដែល កិច្ចប្រជុំក៏បានបន្តពិភាក្សាអំពីការ ប្រមូលធាតុចូលផែនការយុទ្ធសាស្ត្របន្តពីថ្នាក់ជាតិ៥ឆ្នាំបន្ទាប់(២០២៤-២០២៨) និងបញ្ហាប្រឈមមួយចំនួននៃការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ក្រោមការដឹកនាំ សម្របសម្រួលដោយ **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** ក្នុងនោះបានបែងចែកជាក្រុមពិភាក្សា ចំនួនបួនក្រុម រួមមាន៖

-**ក្រុមទី១៖** *ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន កោះកុង សៀមរាប*

-**ក្រុមទី២៖** *ព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី រតនៈគិរី ក្រចេះ*

-**ក្រុមទី៣៖** *កំពង់ឆ្នាំង ត្បូងឃ្មុំ ព្រៃវែង កណ្ដាល តាកែវ កំពត កែប កំពង់ធំ កំពង់ស្ពឺ*

-**ក្រុមទី៤៖** *ព្រះសីហនុ ភ្នំពេញ ស្វាយរៀង បន្ទាយមានជ័យ ឧត្ដរមានជ័យ កំពង់ចាម*

## លទ្ធផលនៃកិច្ចពិភាក្សា៖

**ក្រុមទី១៖**

I. បញ្ហាប្រឈម និងសកម្មភាពដែលមិនបានអនុវត្តក្នុងផែនការយុទ្ធសាស្ត្រជាតិ២០១៩-២០២៣

- បញ្ហាកូវីដ-១៩ នៅក្នុងឆ្នាំ២០២០ ដល់ ឆ្នាំ២០២២ បានរាំងស្ទះដល់ការផ្សព្វផ្សាយពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងរាំងស្ទះការអនុវត្តផែនការ
- ការបណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីនៅក្នុងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិនៅមានកម្រិត
- មានការផ្លាស់ប្ដូរមន្ត្រីទទួលបន្ទុកការងារ ធ្វើឱ្យការអនុវត្តការងារនៅមានកម្រិត
- គម្រោងចុះជួយគាំទ្ររបស់អង្គការដៃគូពុំទាន់ទូលំទូលាយ

- ការផ្សព្វផ្សាយច្បាប់ បទដ្ឋានគតិយុត្តមិនទាន់បានទូលំទូលាយ និងខ្វះការចូលរួមពីប្រជាពលរដ្ឋ
- ជនរងគ្រោះមិនសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ច(ការផ្តល់ព័ត៌មានមិនជាក់លាក់)
- ការទប់ស្កាត់ការរំលោភបំពានតាមប្រព័ន្ធអនឡាញទទួលបានប្រសិទ្ធភាពទាប
- មិនទាន់មានប្រព័ន្ធឆ្លើយតបរហ័ស(Hotline) សម្រាប់ការងារជួញដូរ បានជាក់លាក់
- កិច្ចសហការជាមួយប្រទេសជិតខាងមានការលំបាក
- ជនរងគ្រោះមិនបានទទួលសំណង

II. **ចំណុចដែលធ្វើបានល្អ ហើយគួរធ្វើបន្ថែម**

- មានរចនាសម្ព័ន្ធថ្នាក់ខេត្ត ថ្នាក់ក្រុងស្រុក និងជនបង្គោលឃុំសង្កាត់
- បង្កើតក្រុមការងារទទួលពលករនៅតាមច្រកអន្តរជាតិ និងច្រកតំបន់ និងការបង្កើតមណ្ឌលទទួលពលករនៅខេត្តគោលដៅ
- យុទ្ធនាការរបស់ក្រសួងយុត្តិធម៌ស្តីពីការដោះស្រាយសំណុំរឿងដែលកកស្ទះនៅតុលាការ បានលទ្ធផលល្អ
- បានរៀបចំប្រជុំប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំទិវា១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការបង្កើតវីដេអូខ្លីបែបអប់រំពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព
- ការជ្រើសរើសមន្ត្រីនគរបាលមានសមភាពយេនឌ័រដែលផ្តល់ភាពងាយស្រួលក្នុងការអនុវត្តការងារជាមួយជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។
- មានទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស(ខ្លី និងវែង) និងសេវាបញ្ជូនបានល្អត្រឹមត្រូវ ធ្វើការសម្របសម្រួល និងប្រព័ន្ធបញ្ជូនពលករត្រឡប់ ពិសេសមានមេធាវីសម្តេចតេជោសម្រាប់ជួយជនរងគ្រោះ
- បានបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងមន្ត្រីទទួលបន្ទុក
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពក្រុមហ៊ុនជ្រើសរើសពលករបានល្អ

III. **ការងាររបាយការណ៍ និងសំណូមពរផ្សេងៗ**

- ស្នើសុំទម្រង់របាយការណ៍ដែលមានស្តង់ដារតែមួយ និងមានការបណ្តុះបណ្តាលដល់មន្ត្រីជំនួយការលេខាធិការដ្ឋានបន្ថែម
- សំណើសុំកញ្ចប់ថវិកាសម្រាប់អនុវត្តការងារជួញដូរមនុស្ស
- ស្នើពន្លឿនច្បាប់ស្តីពីការជួញដូរតាមប្រព័ន្ធអនឡាញ
- ស្នើពន្លឿនច្បាប់ស្តីពីការគ្រប់គ្រង និងការពពោះជំនួស

**<u>ក្រុមទី២៖</u>**

I. **បញ្ហាប្រឈម និងសកម្មភាពដែលមិនបានអនុវត្តក្នុងផែនការយុទ្ធសាស្ត្រជាតិ២០១៩-២០២៣**

- សេដ្ឋកិច្ចធ្លាក់ចុះ (ការរីករាលដាលនៃជំងឺកូវីដ-១៩/សញ្ញាប្រមាណៃការចំណាកស្រុក) ខ្វះកិច្ចសហការជាមួយអង្គការដៃគូ និងប្រទេសជាប់ព្រំដែន
- ខ្វះមធ្យោបាយ ថវិកាក្នុងការចុះប្រតិបត្តិការ មិនបានចុះជួបផ្ទាល់ជាមួយពលរដ្ឋតាមសហគមន៍
- ការសហការរវាងរដ្ឋបាលក្រោមជាតិ និងអង្គការដៃគូមួយចំនួននៅមានកម្រិត
- ក្រុមការងារមិនបានប្រជុំទៀងទាត់ និងការបង្ក្រាបបទល្មើសមិនទាន់ពេលវេលា
- សហការមិនបានល្អជាមួយក្រុមការងារយុត្តិធម៌ ក្នុងការប្រមូលទិន្នន័យ និងរបាយការណ៍

II. **ចំណុចដែលធ្វើបានល្អ ហើយគួរធ្វើបន្ថែម**

- បានចុះផ្សព្វផ្សាយផ្ទាល់ដល់មូលដ្ឋានផ្ទាល់ (តាមមណ្ឌលចត្តាឡីស័ក)

- បានផ្សព្វផ្សាយអំពីកលល្បិចរបស់ជនល្មើស មេខ្យល់/ ច្បាប់ តាមប្រព័ន្ធសង្គម និងវេទិកាសាធារណៈ
- ការអនុវត្តការបង្រ្កាប និងការដាក់ទោសជនល្មើសនៅតែអាចធ្វើបាន
- នៅតែជួយជនរងគ្រោះបានទាន់ពេលវេលា
- មានការបណ្តុះបណ្តាលបំនិនវិជ្ជាជីវៈ (បំនិនជីវិត)

III. **ការងាររបាយការណ៍ និងសំណូមពរផ្សេងៗ**

- ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្រ្តីថ្នាក់ក្រោមជាតិ (ការងាររៀបចំរបាយការណ៍ ការអនុវត្តច្បាប់) មិនគួរផ្លាស់ប្តូរអ្នកធ្វើរបាយការណ៍
- សូមថ្នាក់ជាតិជួយសម្របសម្រួលដល់ការផ្តល់របាយការណ៍ពីក្រុមការងារយុត្តិធម៌
- ជួយកៀរគរឱ្យមានអង្គការដៃគូសហការជាមួយ គ.ខ.ប.ជ និងបន្តសហការឱ្យបានល្អប្រសើរ
- ផ្តល់ថវិកាសម្រាប់ការអនុវត្តការងារនៅមូលដ្ឋាន (តាមបណ្តាស្នងការដ្ឋាននគរបាលខេត្ត)
- ផ្តល់ការគាំទ្រពីអង្គការដៃគូក្រៅរដ្ឋាភិបាលដើម្បីជួយតាមបណ្តាខេត្ត
- សូមក្រសួង ស្ថាប័នជួយជំរុញដល់មន្ទីរ អង្គភាពខ្សែបណ្តោយ ក្នុងការចូលរួមសហការអនុវត្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

<u>ក្រុមទី៣៖</u>

I. **បញ្ហាប្រឈម និងសកម្មភាពដែលមិនបានអនុវត្តក្នុងផែនការយុទ្ធសាស្រ្តជាតិ២០១៩-២០២៣**

- ទីតាំងដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចកម្លាំងពលកម្ម (កុមារ) និងការធ្វើអាជីវកម្ម ផ្លូវភេទមួយចំនួន មិនបានសហការពេញលេញ
- ក្រុមការងារទាំង៦ មិនទាន់សហការគ្នាបានល្អ
- ខ្វះធនធានថវិកាក្នុងការចុះអប់រំផ្សព្វផ្សាយ
- ចំណេះដឹងរបស់មន្រ្តីមានកម្រិត នៅមិនទាន់យល់ច្បាស់អំពីច្បាប់ពាក់ព័ន្ធ ពិសេសច្បាប់អន្តរជាតិ
- ការផ្តល់សេវាសង្រ្គោះបឋមនៅមូលដ្ឋានជួបបញ្ហា មន្រ្តីខ្វះជំនាញ គ្មានមន្រ្តីទទួលបន្ទុក ខ្វះថវិកា
- ជនរងគ្រោះមិនសហការ និងគ្មានកន្លែងស្នាក់នៅបណ្តោះអាសន្ន

II. **ចំណុចដែលធ្វើបានល្អ ហើយគួរធ្វើបន្ថែម**

- មានថវិកាសម្រាប់ចុះផ្សព្វផ្សាយតាមបណ្តាក្រុង-ស្រុក តាមរយៈការធ្វើវេទិកាសធារណៈ និងកម្មវិធីផ្សេងៗ
- ផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធ អំពីល្បិចកលជនល្មើស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់សហគមន៍បានទូលំទូលាយ
- ផ្តល់កិច្ចការពារបានល្អ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងផ្តល់សេវាសមស្របបានទាន់ពេលវេលា និងប្រកបដោយគុណភាព
- មានការសហការបានល្អរវាងខេត្តមួយចំនួន អំពីការធ្វើរបាយការណ៍ជូនថ្នាក់កណ្តាល

III. **ការងាររបាយការណ៍ និងសំណូមពរផ្សេងៗ**

- មិនទាន់មានមន្រ្តីទទួលបន្ទុកធ្វើរបាយការណ៍ច្បាស់លាស់ (មានការផ្លាស់ប្តូរមន្រ្តីច្រើន)
- ការផ្តល់របាយការណ៍ពីថ្នាក់អង្គភាពពាក់ព័ន្ធ និងថ្នាក់ក្រុង ស្រុក ខណ្ឌ នៅមានកម្រិត មិនទាន់ពេលវេលា
- ស្នើកញ្ចប់ថវិកាដាច់ដោយឡែកនៅថ្នាក់ជាតិ សម្រាប់បែងចែកថ្នាក់ក្រោមជាតិអនុវត្តបន្ត
- ស្នើសុំវគ្គបណ្តុះបណ្តាលបន្ថែមសម្រាប់មន្រ្តីលេខាធិការដ្ឋាន ពិសេសមន្រ្តីទទួលបន្ទុករបាយការណ៍ និងមន្រ្តីអនុវត្តច្បាប់
- ស្នើសុំឱ្យមានទម្រង់របាយការណ៍រួមមួយសម្រាប់អនុវត្ត

ក្រុមទី៤៖

I. បញ្ហាប្រឈម និងសកម្មភាពដែលមិនបានអនុវត្តក្នុងផែនការយុទ្ធសាស្ត្រជាតិ២០១៩-២០២៣

- ការធ្វើចំណាកស្រុកឆ្លងដែន ដើម្បីស្វែងការងារធ្វើដោយប្រថុយប្រថាន តាមមេខ្យល់អូសទាញនៅតែបន្តមានពិសេសលំហូរឆ្លងដែនតាមច្រករបៀង(ស្ទើបិទច្រករបៀង)
- កិច្ចសហការជាមួយខេត្តជាប់ព្រំដែននៅមានកម្រិត
- ជនរងគ្រោះមួយចំនួនមិនសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការផ្តល់ចម្លើយរកមេខ្យល់
- ខ្វះការយកចិត្តទុកដាក់ និងការចូលរួមរបស់កុមារងាយរងគ្រោះនៅតាមទីតាំងកម្សាន្ត ភ្លើងស្តុប និងកុមារតាមផ្ទះ
- ខ្វះថវិកា និងមធ្យោបាយក្នុងចុះស្រាវជ្រាវព័ត៌មាននៅតាមមូលដ្ឋាន
- ពិបាកកំណត់អត្តសញ្ញាណជនរងគ្រោះ និងមិនមានមណ្ឌលទទួលពលករបានសមរម្យ
- កែសម្រួលទម្រង់របាយការណ៍ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ និងសូចនាករដែលមានលក្ខណៈជាប្រព័ន្ធ និងអាចវាយតម្លៃបាន
- មិនទាន់មានយុទ្ធសាស្ត្រស្តង់ដាររួមសម្រាប់បង្ការទប់ស្កាត់ រវាងប្រទេសបញ្ជូន និងប្រទេសទទួល
- ជនល្មើសមានអំណាច និងមានរចនាសម្ព័ន្ធចាត់តាំងខ្ពស់
- មានការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកការងារ
- ខ្វះការប្រៀបធៀបទិន្នន័យបង្ក្រាប និងការផ្តន្ទាទោស

II. ចំណុចដែលធ្វើបានល្អ ហើយគួរធ្វើបន្ថែម

- មានកិច្ចសហការប្រតិបត្តិល្អរវាងក្រុមការងារជំនាញទាំង៦ ដែលអាចជួយជនរងគ្រោះបានទាន់ពេលវេលា
- មានការអប់រំ ផ្សព្វផ្សាយបានទូលំទូលាយដល់សហគមន៍ និងតាមមូលដ្ឋាន
- ធ្វើរបាយការណ៍ទៀងទាត់ និងទាន់ពេលវេលា

III. ការងាររបាយការណ៍ និងសំណូមពរផ្សេងៗ

- ជំរុញការអនុវត្តករណីដែលនៅសេសសល់ ដោយចាត់កម្លាំងចុះស្រាវជ្រាវ ឈានទៅចាប់ខ្លួនមុខសញ្ញាចាស់ និងមុខសញ្ញាដែលមានដីកាយកមកផ្តន្ទាទោសតាមច្បាប់
- ជំរុញ និងពន្លឿនច្បាប់ករណីពពោះជំនួស ឱ្យបានឆាប់រហ័ស
- ការជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ និងការគ្រប់គ្រងល្បែងអនឡាញខុសច្បាប់
- ការទូទាត់សំណងដល់ជនរងគ្រោះឱ្យបានទាន់ពេលវេលា

បន្ទាប់ពីមានការជជែក ពិភាក្សាតាមក្រុមនីមួយៗរួចមក **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** ក៏បានធ្វើការសន្និដ្ឋានជារួមលើការអនុវត្តការងារកន្លង ដោយសារពេលខ្លះជាការទទួលខុសត្រូវរបស់ថ្នាក់ជាតិ និងពេលខ្លះជាការទទួលខុសត្រូវរបស់ថ្នាក់ក្រោមជាតិខ្លួនឯងផ្ទាល់ និងបានរំលឹកពីគោលបំណងនៃការបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបទៅនឹងការលើកឡើងមួយចំនួនដែលថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បង្កើតឡើងដើម្បីដណ្តើមការងារ ឬជ្រៀតជ្រែកការងារតាមបណ្តាក្រសួង ស្ថាប័នមួយចំនួន តាមពិតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាស្ថាប័នសម្របសម្រួល និងពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថប័នពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពការងារឱ្យកាន់តែមានប្រសិទ្ធភាពការងារខ្ពស់ លោកជំទាវបានបញ្ជាក់ថា គឺដោយសារយើងពិនិត្យឃើញពីភាពមិនជោគជ័យនៃការកង្វះកិច្ចសហការ ដោយឡែកជនល្មើសតែងឆ្លៀតឱកាសរកចន្លោះប្រហោង ដើម្បីប្រព្រឹត្តបទល្មើស ជាក់ស្តែងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជាដើម បើទោះជាមន្ត្រីរបស់យើងគ្រប់ជាន់ថ្នាក់ ខិតខំប្រឹងប្រែងទាំងថ្ងៃ ទាំងយប់ ហាលខ្យល់ ហាលភ្លៀង យ៉ាងណាក៏ដោយ តែជនល្មើសនៅតែឆ្លៀតឱកាសបាន។

លោកជំទាវលើកឡើងថា បើយើងចង់ទទួលបានជោគជ័យ គឺវាពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងការប្តេជ្ញាចិត្ត ឥឡូវនេះរចនាសម្ព័ន្ធមានហើយដែលបង្កើតឡើងព្រះរាជក្រឹត្យ និងមានថ្នាក់ដឹកនាំកំពូលៗដឹកនាំការងារ រួមទាំងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ ដែលដឹកនាំដោយអភិបាលរាជធានី ខេត្ត និងមន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួនទៀត។ ទាក់ទងនឹងលិខិតបទដ្ឋាន គោលការណ៍ ច្បាប់ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គឺយើងមានគ្រប់អស់ហើយ នៅតែថាយើងត្រូវធ្វើឬអត់? បើធ្វើហើយត្រូវមានរបាយការណ៍ បើអត់របាយការណ៍មានន័យថាអត់ធ្វើ។ លោកជំទាវក៏បានសុំឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់ ពង្រឹងការទទួលខុសត្រូវលើការងាររៀងៗខ្លួន ពិសេសយកចិត្តទុកដាក់ខ្ពស់លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយសារជនល្មើសមានល្បិចកលច្រើន និងបច្ចេកវិទ្យាខ្ពស់ ដែលទាមទារឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវពង្រឹងសមត្ថភាពខ្លួនឯង តាមរយៈការបណ្តុះបណ្តាលបន្ថែមពាក់ព័ន្ធនឹងច្បាប់ លិខិតបទដ្ឋានដែលមានស្រាប់។

ពាក់ព័ន្ធនឹងកិច្ចសហការ លោកជំទាវ បានលើកទឹកចិត្តឱ្យខេត្ត និងស្ថាប័នពាក់ព័ន្ធ ជួបប្រជុំគ្នាឱ្យបានញឹកញាប់ និងទៀតទាត់ ទាំងកិច្ចប្រជុំកម្រិតបច្ចេកទេស ឬប្រជុំឆ្លងរបាយការណ៍ប្រចាំខែ និងលើកពីផែនការសកម្មភាពរបស់យើងប្រចាំឆ្នាំ ដើម្បីពិភាក្សារកចំណុចខ្វះខាតបញ្ហាប្រឈម ដំណោះស្រាយផ្សេងៗ និងបែងចែកការងារគ្នាធ្វើ ការសហការជាមួយអង្គការដៃគូ ការស្វែងរកថវិកា គាំទ្រសម្រាប់ការចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ លោកជំទាវបញ្ជាក់ថា តាមការលើកឡើងរបស់ខេត្តខ្លះមិនទាន់មានបញ្ជីរចនាសម្ព័ន្ធនៅឡើយ ដែលធ្វើឱ្យពិបាក និងរាំងស្ទះការអនុវត្តការងារ។

ជាចុងបញ្ចប់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ បានថ្លែងអំណរគុណ ចំពោះសមាជិក សមាជិកា នៃអង្គពិធី និងបញ្ជាក់ជាថ្មី ឆ្លើយតបទៅនឹងសំណូមពរ អំពីការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ថានិងមានការបណ្តុះបណ្តាលជាបន្តបន្ទាប់ ហើយនៅមានការជួបគ្នាបន្តទៀត ព្រោះនៅមានការងារច្រើនត្រូវធ្វើជាមួយគ្នា។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃច័ន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក **អ៊ុច ចាន់ធា**

**គោរពជូន**

**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃព្រ.ហ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០២៣

**ប្រធានលេខាធិការធិការដ្ឋានរដ្ឋបាល សរុប**

21/12/23

**ឧត្តមសេនីយ៍ទោ ហាង ជីវ័ន្ត**

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃព្រ.ហ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០២៣

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.**ប៉ុណ្ណា សំខាន់**